*បកប្រែក្រៅផ្លូវការ*

**លិខិតរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០២៥**
**ផ្ញើជូន ឯកឧត្តម Asim Iftikhar Ahmad**
**ឯកអគ្គរដ្ឋទូតតំណាងអចិន្ត្រៃយ៍នៃប្រទេសប៉ាគីស្ថាន ប្រចាំអង្គការសហប្រជាជាតិ និងជាប្រធានប្តូរវេននៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រាប់ខែកក្កដា ឆ្នាំ២០២៥**

------------------------

ខ្ញុំសូមជម្រាបជូន ឯកឧត្តម ក៏ដូចជាសមាជិកដទៃទៀតនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជ្រាបជាបន្ទាន់ អំពីការឈ្លានពានដោយអាវុធមកលើប្រទេសកម្ពុជានាពេលថ្មីៗនេះ ដោយកងកម្លាំងយោធាថៃ នៅតាមព្រំដែនកម្ពុជា-ថៃ ដូចតទៅ៖

ចាប់តាំងពីព្រឹកព្រលឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ កងកម្លាំងប្រដាប់អាវុធថៃបានបើកការវាយប្រហារដោយមានការគិតទុកជាមុន និងចេតនាបង្កហេតុ មកលើទីតាំងរបស់កម្ពុជាតាមបណ្តោយតំបន់ព្រំដែន រួមមានតំបន់ប្រាសាទតាមាន់ធំ ប្រាសាទតាក្របី តំបន់មុំបី ដែលស្ថិតក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។

កម្ពុជាថ្កោលទោសយ៉ាងម៉ឺងម៉ាត់បំផុត និងមានសេចក្តីទោមនស្សយ៉ាងខ្លាំង ចំពោះការឈ្លានពាន ដោយកងកម្លាំងប្រដាប់អាវុធរបស់ព្រះរាជាណាចក្រថៃដែលមានការគិតទុកជាមុន និងចេតនាបង្កហេតុនេះ។ ការវាយប្រហារដោយយោធានេះ បានបំពានយ៉ាងជាក់ស្តែងលើគោលការណ៍មិនឈ្លានពានគ្នា និងការដោះស្រាយវិវាទដោយសន្តិវិធី ដែលជាមូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ និងគោលការណ៍ចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ស្តីពីការហាមមិនឱ្យធ្វើការគំរាមកំហែង ឬប្រើប្រាស់កម្លាំងឈ្លានពានបូរណភាពទឹកដីនៃរដ្ឋណាមួយ ក៏ដូចជាការមិនគោរពចំពោះស្មារតីអ្នកជិតខាងល្អ ដែលកម្ពុជាបានខិតខំប្រកាន់ខ្ជាប់រហូតមកដល់ពេលនេះ។

ប្រឈមមុខនឹងការឈ្លានពានដ៏ព្រហើននេះ កងទ័ពកម្ពុជាគ្មានជម្រើសអ្វីក្រៅពីធ្វើការវាយបកដើម្បីការពារខ្លួន ការពារអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា។ កម្ពុជាអំពាវនាវឱ្យថៃបញ្ឈប់រាល់ទង្វើអរិភាពជាបន្ទាន់ ដកកម្លាំងទៅខាងព្រំដែនរបស់ខ្លួន និងចៀសវាងសកម្មភាពញុះញង់បង្កហេតុដែលអាចធ្វើឱ្យស្ថានការណ៍កាន់តែតានតឹង។

ខ្ញុំសូមអនុញ្ញាតរំលឹកថា ភាពតានតឹងនៅតាមព្រំដែន និងអរិភាពប្រដាប់អាវុធនៅតែបន្តកើតមានរវាងកម្ពុជា និងថៃ បើទោះបីជាមានអនុសញ្ញាបារាំង-សៀមឆ្នាំ ១៩០៤ និងសន្ធិសញ្ញាឆ្នាំ ១៩០៧ ក៏ដូចជាផែនទីដែលផលិតដោយគណៈកម្មការព្រំដែនរវាងឥណ្ឌូចិន និងសៀម ដែលបង្កើតឡើងដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិទាំងពីរ និងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការវាស់

វែងនិងខណ្ឌសីមាព្រំដែនគោកឆ្នាំ ២០០០ (MOU-2000) ដែលតាមរយៈ MOU ភាគីទាំងពីរបាន ប្តេជ្ញារួមគ្នាបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរ ផ្អែកលើឯកសារច្បាប់ទាំងនេះ។

ដូចករណីមុនៗដែរ អរិភាពតាមព្រំដែនរវាងប្រទេសទាំងពីរនាពេលបច្ចុប្បន្ននេះ កើតចេញពីការដែលប្រទេសថៃទទូចទាមទារអធិបតេយ្យដែនដីនៅតំបន់ព្រំដែន ផ្អែកលើមូលដ្ឋាននៃផែនទីដែលថៃខ្លួនឯងបានគូសជាឯកតោភាគី គ្មានមូលដ្ឋានច្បាប់ និងផ្ទុយពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរព MOU-2000។ ដើម្បីជាលេសសម្រាប់ការឈ្លានពានប្រដាប់វុធនាពេលបច្ចុប្បន្ន ប្រទេសថៃក៏បានធ្វើការចោទប្រកាន់ដោយគ្មានមូលដ្ឋានមកលើកម្ពុជាជុំវិញការផ្ទុះគ្រាប់មីន បន្ទាប់ពីទាហានថៃបានដើរល្បាតខុសផ្លូវដែលប្រទេសទាំងពីរបានសម្របសម្រួល និងព្រមព្រៀងគ្នាពីកន្លងមក ហើយថៃមទាំងបានបង្កើតផ្លូវថ្មីមួយឆ្លងកាត់ទឹកដីកម្ពុជា នៅក្នុងតំបន់ដែលមានការទទួលស្គាល់ និងត្រូវបានចុះបញ្ជីជាផ្លូវការថាជាចំការមីន។

ជាការគួរឲ្យសោកស្តាយដែលមានអំពើឈ្លានពាននេះកើតឡើង ខណៈកម្ពុជាកំពុងបន្តខិតខំយ៉ាងសកម្មដើរតាមផ្លូវច្បាប់ ដោយសន្តិវិធី និងមិនលម្អៀងដើម្បីដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ជាមួយថៃ តាមរយៈយន្តការទ្វេភាគី និងអន្តរជាតិ។ ដូចដែលសហគមន៍អន្តរជាតិបានដឹងហើយថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៥ ក្នុងការបញ្ជូនទៅសុំតុលាការយុត្តិធម៌អន្តរជាតិធ្វើការវិនិច្ឆ័យចំពោះតំបន់ជម្លោះចំនួន៤ គឺតំបន់មុំបី ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច និងប្រាសាទតាក្របី។ កំណើនភាពតានតឹងផ្នែកយោធានេះ ត្រូវបានបង្កឡើងដោយប្រទេសថៃ បើទោះបីជាមានការអំពាវនាវក្នុងតំបន់ និងអន្តរជាតិឱ្យមានការអត់ធ្មត់ និងដំណោះស្រាយដោយសន្តិវិធី និងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការសន្ទនា រួមទាំងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោកកម្ពុជា-ថៃ (JBC) នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤-១៥ ខែមិថុនា ឆ្នាំ ២០២៥ កន្លងទៅ។

យោងលើការឈ្លានពានយ៉ាងគឃ្លើនរបស់ថៃនាពេលថ្មីៗនេះ ដែលបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ ខ្ញុំសូមស្នើឱ្យ **ឯកឧត្តម** កោះប្រជុំក្រុមប្រឹក្សាសន្តិសុខជាបន្ទាន់ ដើម្បីបញ្ឈប់ការឈ្លានពានរបស់ថៃ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ប្រសិនបើ **ឯកឧត្តម** អាចផ្សព្វផ្សាយលិខិតនេះ ជូនដល់សមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានយ៉ាងជ្រាលជ្រៅអំពីខ្ញុំ៕

(ហត្ថលេខា)

**ហ៊ុន ម៉ាណែត**